ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០០៤ សហវ.ក្រប

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១១

# ប្រកាស
## ស្តីពី
## ការកែប្រែបំពេញបន្ថែមឯកសារក្នុងទម្រង់បែបបទសម្រាប់ការចុះបញ្ជីពន្ធដារ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទីទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុ មូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃ ទី២៨ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើង ទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

# សម្រេច

**ប្រការ១:** ដូចមានចែងក្នុងមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ និងផ្នែកទី១៣.១ នៃជំពូកទី១៣ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុង១៥ថ្ងៃ ក្រោយពីបុគ្គលនោះធ្វើសកម្មភាពសេដ្ឋកិច្ច ។ បុគ្គលទាំងឡាយ ត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីមានការផ្លាស់ប្តូរ អាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង សមាសភាពអ្នកទទួលបន្ទុកកិច្ចការពន្ធដារ ឬក្រោយពីមានការផ្ទេរ ឬការបញ្ឈប់អាជីវកម្ម ។

ពាក្យសុំចុះបញ្ជី និងលិខិតជូនដំណឹង ត្រូវអនុវត្តតាមទម្រង់លិខិតឯកភាព និងបែបបទកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ ។ ពាក្យសុំចុះបញ្ជីត្រូវមានភ្ជាប់ឯកសារ ដូចតទៅៈ

ក- ចំពោះសហគ្រាសនីតិបុគ្គល

១.វិញ្ញាបនបត្រ និងលិខិតបញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម ដែលបានបង់ពន្ធប្រថាប់ត្រា អមភ្ជាប់ច្បាប់ថតចម្លងនៃសំណុំឯកសារសម្រាប់អនុវត្តការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដែលជាអាទិ៍មានៈ ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម លក្ខន្តិកៈសហគ្រាស ពាក្យសុំចុះផ្សាយក្នុងព្រឹត្តិបត្រពាណិជ្ជកម្ម...។ល។

២.ច្បាប់ថតចម្លងអត្តសញ្ញាណបណ្ណរបស់អ្នកដឹកនាំសហគ្រាស ជាមួយនឹងរូបថតទំហំ ៤x៦ ចំនួន ០២សន្លឹក និងច្បាប់ថតចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ជនជាតិខ្មែរ ។ ច្បាប់ថតចម្លងលិខិតឆ្លងដែន អមភ្ជាប់ដោយច្បាប់ថតចម្លងនៃបណ្ណស្នាក់នៅ ផ្តល់ដោយ ឬមានការបញ្ជាក់ពីការិយាល័យ ជនបរទេស នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដែលជនបរទេសនោះ ស្នាក់នៅ ។

៣.លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដែលចេញដោយស្ថាប័នមានសមត្ថកិច្ចដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំពោះ វិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាបណ្ណផ្នែកសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនទ្រព្យ ក្រសួង ឬមន្ទីរ ទេសចរណ៍ ចំពោះសកម្មភាពអាជីវកម្ម សណ្ឋាគារ ភោជនីយដ្ឋាន ទីភ្នាក់ងារទេសចរណ៍... ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះសកម្មភាពអាជីវកម្មសាងសង់ជាដើម ។ល។

៤.វិញ្ញាបនបត្រចុះបញ្ជី របស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់) ។

៥.ព័ត៌មានអចលនទ្រព្យ នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស តាមគំរូឯកភាពដែលផ្តល់ជូនដោយអគ្គនាយកដ្ឋានពន្ធដារ និងកិច្ចសន្យាជួលទីតាំង (ប្រសិនបើមានការជួលទីតាំងសម្រាប់ប្រកបអាជីវកម្ម) និងលិខិតឆ្លើយប្រកាសអំពីការជួលរបស់ម្ចាស់ទីតាំង។

៦.ច្បាប់ថតចម្លងវិក្កយបត្រទឹក និងអគ្គិសនី (រយៈពេល ០៣ខែ ចុងក្រោយ) នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស ។

ខ- ចំពោះសហគ្រាសឯកបុគ្គល

១.វិញ្ញាបនបត្រ និងលិខិតបញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម អមភ្ជាប់មកជាមួយច្បាប់ថតចម្លងសំណុំឯកសារសម្រាប់អនុវត្តការចុះបញ្ជីពាណិជ្ជកម្ម ។

២.ច្បាប់ថតចម្លងអត្តសញ្ញាណបណ្ណរបស់អ្នកដឹកនាំសហគ្រាស ជាមួយនឹងរូបថតទំហំ ៤x៦ ចំនួន ០២សន្លឹក និងច្បាប់ថតចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ជនជាតិខ្មែរ ។ ច្បាប់ថត

ចម្លងលិខិតឆ្លងដែន អមភ្ជាប់ដោយច្បាប់ថតចម្លងនៃបណ្ណស្នាក់នៅ ផ្តល់ដោយ ឬមានការបញ្ជាក់ពីការិយាល័យ ជនបរទេស នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ដែលជនបរទេសនោះ ស្នាក់នៅ ។

៣.លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ដូចជា មន្ទីរទេសចរណ៍ ចំពោះសកម្មភាព អាជីវកម្មសណ្ឋាគារ ភោជនីយដ្ឋាន ទីភ្នាក់ងារទេសចរណ៍... មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះ សកម្មភាពអាជីវកម្មសាងសង់ ជាដើម ។ល។

៤.ព័ត៌មានអចលនទ្រព្យ នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស តាមគំរូឯកភាពដែលផ្តល់ជូនដោយអគ្គនាយកដ្ឋានពន្ធដារ និងកិច្ចសន្យាជួលទីតាំង (ប្រសិនបើមានការជួលទីតាំងសម្រាប់ប្រកបអាជីវកម្ម) និងលិខិតឆ្លើយប្រកាសអំពីការជួលរបស់ម្ចាស់ទីតាំង ។

៥.ច្បាប់ថតចម្លងវិក្កយបត្រទឹក និងអគ្គិសនី (រយៈពេល ០៣ខែ ចុងក្រោយ) នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស ។

**ប្រការ២:** ដូចមានចែងក្នុងមាត្រា១០៣ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជី ចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី តែពុំបានមកចុះបញ្ជី ហើយក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី ។

**ប្រការ៣:** ដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវបានចាត់ទុកជាអំពើរាំងស្ទះ ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ (ដែលត្រូវទទួលរងទោសទណ្ឌ ដូចមានចែងក្នុងមាត្រា ១៣៣ និងមាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ) ក្នុងករណីដែល បុគ្គលមិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ឬមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ ពីការផ្លាស់ប្តូរផ្សេងៗ ដូចមានចែងក្នុងប្រការ ១ ។

**ប្រការ៤:** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាស នេះឱ្យបានល្អប្រសើរ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

<u>ចម្លងជូន៖</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី } "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់សាលារាជធានី-ខេត្ត }
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

# ពាក្យសុំចុះបញ្ជីពន្ធដារ

នាមត្រកូល និងនាមខ្លួន៖........................................................................ សញ្ជាតិ៖...........................................
អាសយដ្ឋានបច្ចុប្បន្ន៖...............................................................................................................................
អត្តសញ្ញាណប័ណ្ណ☐ លិខិតឆ្លងដែនលេខ☐..........................................ចុះថ្ងៃទី...........ខែ...........ឆ្នាំ..............
ក្នុងនាមជា៖ ស្ថាបនិក ☐ អភិបាល ☐ អាណត្តិគាហក☐ ម្ចាស់សហគ្រាស☐
នៃ ក្រុមហ៊ុន☐ សហគ្រាស☐៖...............................................................................................
Name of Enterprise: ...............................................................................................

ខ្ញុំបាទ/នាងខ្ញុំ សុំចុះឈ្មោះ ក្រុមហ៊ុន សហគ្រាស ដូចមានឈ្មោះខាងលើ ក្នុងបញ្ជីពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម៖

១. វិញ្ញាបនបត្រ បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម☐
២. លិខិតបញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម☐
៣. ច្បាប់ថតចម្លងនៃសំណុំឯកសារសម្រាប់អនុវត្តការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម៖
- ច្បាប់ថតចម្លងពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម☐
- ច្បាប់ថតចម្លងលក្ខន្តិកៈសហគ្រាស☐
- ច្បាប់ថតចម្លងពាក្យសុំចុះផ្សាយក្នុងព្រឹត្តិបត្រពាណិជ្ជកម្ម☐
- ច្បាប់ថតចម្លងលិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារ☐
- ច្បាប់ថតចម្លងអត្តសញ្ញាណបណ្ណ☐ ឬ ច្បាប់ថតចម្លងលិខិតឆ្លងដែន(សម្រាប់ជនបរទេស)☐ នៃស្ថាបនិក☐ អភិបាល☐ អាណត្តិគាហក☐ ម្ចាស់សហគ្រាស☐និងរូបថត៤x៦ចំនួន០២សន្លឹក

៤. ច្បាប់ថតចម្លងសៀវភៅគ្រួសារ☐ ឬសៀវភៅស្នាក់នៅ☐ ឬច្បាប់ថតចម្លងនៃបណ្ណស្នាក់នៅ (សម្រាប់ជនបរទេស)ផ្តល់ដោយ ឬមានការបញ្ជាក់ពីការិយាល័យជនបរទេស នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត☐ នៃស្ថាបនិក☐ អភិបាល☐ អាណត្តិគាហក☐ ម្ចាស់សហគ្រាស☐
៥. លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម ចេញដោយស្ថាប័នមានសមត្ថកិច្ច☐
៦. វិញ្ញាបនបត្រចុះបញ្ជីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា☐
៧. កិច្ចសន្យាជួលទីតាំង (ប្រសិនបើមានការជួលទីតាំងសម្រាប់ប្រកបអាជីវកម្ម)☐ ភ្ជាប់ដោយលិខិតឆ្លើយប្រកាសអំពីការជួលរបស់ម្ចាស់ទីតាំង☐
៨. វិក្កយបត្រទឹក និងអគ្គិសនី (ច្បាប់ថតចម្លងរយៈពេល ០៣ខែ ចុងក្រោយ) នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស☐
៩. ព័ត៌មានអចលនទ្រព្យ នៃទីតាំងរបស់គ្រឹះស្ថានជាគោលដើម ឬទីចាត់ការរបស់សហគ្រាស ☐
១០. សលាកបត្រព័ត៌មានសហគ្រាស/ក្រុមហ៊ុន☐
១១. ពាក្យស្នើសុំចុះបញ្ជីអាករលើតម្លៃបន្ថែម (សម្រាប់របបស្វ័យប្រកាស)☐
១២. លិខិតប្រកាសអាករលើជលបេរ និងពន្ធលើប្រាក់ចំណេញ "របបមៅការ"☐
១៣. លិខិតប្រកាសពន្ធប៉ាតង់ប្រចាំឆ្នាំសម្រាប់របបមៅការ☐ ឬរបបស្វ័យប្រកាស☐

ពាក្យសុំចុះបញ្ជីពន្ធដារនេះមានចំនួន..............ច្បាប់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....................................................ឋានៈ/តួនាទី.......................................................នៃសហគ្រាស/ក្រុមហ៊ុនខាងលើសូមធានាថា ឯកសារ និងព័ត៌មានទាំងអស់ភ្ជាប់នៅក្នុងពាក្យសុំចុះបញ្ជីពន្ធដារនេះ ពិតជាត្រឹមត្រូវ ។ ខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទាំងឡាយជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ ។

ធ្វើនៅ........................, ថ្ងៃទី............ខែ............ឆ្នាំ............

បានទទួលពាក្យសុំចុះបញ្ជី
ថ្ងៃទី............ខែ............ឆ្នាំ............
មន្ត្រីពន្ធដារ

*កំណត់សម្គាល់៖ សូមគូសសញ្ញា ✓ នៅក្នុងប្រអប់ចំពោះឯកសារដែលមានភ្ជាប់នៅក្នុងពាក្យសុំចុះបញ្ជីពន្ធដារ។*